មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

# របាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅកម្ពុជា

**រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សូមចេញផ្សាយនូវរបាយការណ៍ប្រចាំឆ្នាំស្តីពី*ស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅក្នុងប្រទេសកម្ពុជា* ដែលគម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា និងគម្រោងលើកកម្ពស់ និងការពារសេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យរួមគ្នាតាក់តែងឡើង។ លោកអ្នកអាចទាញយករបាយការណ៍ជាមួយតំណភ្ជាប់នេះ សម្រាប់ភាសាខ្មែរ និងភាសាអង់គ្លេស។

របាយការណ៍នេះបង្ហាញពីទិដ្ឋភាពទូទៅនៃស្ថានភាពនៃសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាននៅក្នុងប្រទេសកម្ពុជា និងលទ្ធភាពរបស់សាធារណជនទូទៅក្នុងការអនុវត្តសិទ្ធិទាំងនេះនៅក្នុងអំឡុងពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១។ របាយការណ៍នេះក៏បង្ហាញទិន្នន័យសំខាន់ៗរួមមានការដកហូតអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយ ចំនួន៧ អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សមួយចំនួនបានប្រឈមបណ្តឹង និងការបំភិតបំភ័យ អ្នកសារព័ត៌មាន និងប្រជាពលរដ្ឋប្រឈមក្នុងការទទួលព័ត៌មាន និងការដាក់កំហិតខ្លួនឯងនៅតែបន្តកើនឡើង។ ទិន្នន័យនេះក៏មានការរួមបញ្ចូលនូវសក្ខីកម្មពីអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សដែលរងនូវបញ្ហាប្រឈមនៅពេលដែលពួកគេអនុវត្តការងាររបស់ខ្លួនផងដែរ។

របាយការណ៍នេះ ក៏បង្ហាញពីកង្វះសង្គតិភាពនៃច្បាប់ជាតិទៅនឹងបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តជាតិ ដែលបានអនុញ្ញាតិឱ្យរដ្ឋាភិបាលកាត់បន្ថយ និងរឹតត្បិតសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន របស់ប្រជាពលរដ្ឋ អ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។ ជាចុងក្រោយ របាយការណ៍ក៏បានផ្តល់អនុសាសន៍ជាច្រើនដល់រដ្ឋាភិបាល ដើម្បីឱ្យមានវិធានការជាក់លាក់ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនស្របតាមបទដ្ឋានច្បាប់អន្តរជាតិ ដើម្បីការពារ និងលើកកម្ពស់សេរីភាពខាងការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា។

***អំពីគម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា និងគម្រោងលើកកម្ពស់ និងការពារសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជា៖*** ដើម្បីឆ្លើយតបនឹងការរឹតត្បិតសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន គម្រោងបង្កើនការគោរពសិទ្ធិនៅកម្ពុជា និងគម្រោងលើកកម្ពស់ និងការពារសេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ មានគោលបំណងបង្ហាញពីការតាក់តែងច្បាប់ជាវិជ្ជមានដើម្បីនាំឱ្យច្បាប់កម្ពុជាមានសង្គតិភាពជាមួយបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ គម្រោងក៏ជំរុញឱ្យមានភាពចម្រុះនៃប្រព័ន្ធផ្សព្វផ្សាយតាមរយៈសារព័ត៌មានឯករាជ្យអាចធ្វើការស៊ើបអង្កេត និងរាយការណ៍គ្រប់បញ្ហាដែលមានប្រយោជន៍សម្រាប់សាធារណជន ដោយមិនមានការភ័យខ្លាច និងធានាថារាល់ស្ថាប័នរដ្ឋាភិបាល និងឯកជនដែលមានមុខងារសាធារណៈត្រូវអនុវត្តនូវគោលការណ៍នៃការបង្ហាញព័ត៌មានជាអតិបរិមា។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួលគម្រោងការលើកកម្ពស់ និងការពារសេរីភាពខាងការបញ្ចេញមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ នៃ ម.ស.ម.ក លោក ហួន ផន តាមរយៈទូរសព្ទ ០៧០ ៧៥៧ ៨៨៤ ឬអ៊ីម៉ែល phorn@cchrcambodia.org ៕

<u>ចប់</u>

## បណ្ណាធិការ៖

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា( "ម.ស.ម.ក" )បានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (MOCT SOS-Torture Network) និងជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" និងទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។